ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងពាណិជ្ជកម្ម
អគ្គនាយកដ្ឋានពាណិជ្ជកម្មអន្តរជាតិ
នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ
លេខ:១១៤..........សហអ

**សូមគោរពជូន**
**ឯកឧត្តមទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងពាណិជ្ជកម្ម**

កម្មវត្ថុ: របាយការណ៍នៃកិច្ចប្រជុំរវាង DICO និង IAs ប្រចាំខែមេសា

យោង: លិខិតអញ្ជើញលេខ ១៧០៨ ពណ-សហអ ចុះថ្ងៃទី ២៤ មេសា ២០១២

តបតាមកម្មវត្ថុ និង យោងខាងលើ ខ្ញុំបាទមានកិត្តិយសសូមគោរពជូន និង រាយការណ៍ជូន **ឯកឧត្តម ទេសរដ្ឋមន្ត្រី** មេត្តាជ្រាបថា: កាលពីថ្ងៃទី ២៧ មេសា ២០១២ DICO បានរៀបចំកិច្ចប្រជុំប្រចាំខែ ជាមួយភ្នាក់ងារអនុវត្តគម្រោង (Implementing Agencies) ដើម្បីជម្រុញការអនុវត្តន៍គម្រោងTDSP ។ ខ្ញុំបាទសូមអនុញ្ញាតរាយការណ៍ជូននូវចំណុចសំខាន់ៗដូចខាងក្រោម:

I- **វឌ្ឍនភាពនៃការអនុវត្តន៍គម្រោង** TDSP

- ថវិការបស់ TDSP ៖ ថវិកាគម្រោង TDSP សរុបមានចំនួន $12.35លាន ដែលគិតត្រឹមថ្ងៃទី៣១ ធ្នូ ២០១១ បានចំណាយអស់ $2.4លាន (19.4%)សម្រាប់ពេលខាងមុខមានគម្រោងត្រូវចាយតាមរយៈ MOU ទាំង 21 ដែលមានទឹកប្រាក់ចំនួន $6.26 លាន និងចំណាយប្រតិបត្តិការលេខាធិការដ្ឋាន DICO មានទឹកប្រាក់ $900.000 ។ ដូច្នេះទឹកប្រាក់ដែលនៅសល់ចំនួន $2.7លាន រក្សាទុកសម្រាប់គម្រោងថ្មីៗក្នុងឆ្នាំ ២០១២ និង ២០១៣ ។

II- **ការពិនិត្យឡើងវិញលើ** MoU

រហូតមកដល់ពេលនេះ IAs បានផ្ញើលិខិតស្នើសុំធ្វើវិសោធនកម្មលើ MoU មកលេខា

ធិការដ្ឋាន DICO រួចអស់ហើយ ក៏ប៉ុន្តែ IAs ខ្លះបានកំណត់ពេលវេលា (Timeframe) ដើម្បីបន្តអនុវត្តន៍គម្រោងរបស់ខ្លួនមិនច្បាស់លាស់ និងខ្លះទៀតមានរយៈពេលលើសពីកម្រឹតដែល DICO សម្រេច ។ ចំពោះបញ្ហានេះ DICO បានឯកភាពឲ្យ IAs ពិភាក្សាជាមួយប្រធានរបស់ខ្លួនសិន រួចហើយផ្ញើលិខិតជាផ្លូវការផ្ញើមក DICO ។ រីឯគម្រោងដែលត្រូវការពេលវេលាវែង DICO នឹងដាក់ជូន IC ជាអ្នកសម្រេច ដោយតម្រូវឲ្យ IAs មកការពារគម្រោងរបស់ខ្លួនដោយផ្ទាល់ ។

## III- ការបន្តកិច្ចសន្យារបស់ទីប្រឹក្សាក្រោមគម្រោង TDSP

នៅក្នុងការបន្តកិច្ចសន្យារបស់ទីប្រឹក្សាក្រោមគម្រោង TDSP យើងត្រូវការឯកសារដែលចាំបាច់រួមមាន ៖

- លិខិតស្នើសុំជាផ្លូវការរបស់ IAs ដែលចែងពីតំរូវការពេលវេលាច្បាស់លាស់ ។
- របាយការណ៍សកម្មភាព និងលទ្ធផលការងាររបស់ទី ប្រឹក្សានីមួយៗ ។
- ការវាយតម្លៃអំពីការអនុវត្តន៍ការងាររបស់ទីប្រឹក្សាទាំងនោះ ។

## IV- ការធ្វើសវនកម្មរបស់គម្រោង TDSP

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និងធនាគារពិភពលោកបានជ្រើសរើសក្រុមហ៊ុនសវនកម្មឯករាជ្យមួយដើម្បីធ្វើការត្រួតពិនិត្យគម្រោង TDSP ដែលបច្ចុប្បន្នកំពុងតែធ្វើការត្រួតពិនិត្យនៅក្នុងនាយកដ្ឋានDICO ហើយនៅថ្ងៃទី ០២ ឧសភា ២០១២ ក្រុមនេះនឹងចុះត្រួតពិនិត្យ IAs មួយចំនួនគឺ ៖ នាយកដ្ឋានរដ្ឋបាលរបស់ក្រសួងពាណិជ្ជកម្ម, នាយកដ្ឋានជម្រុញពាណិជ្ជកម្ម, អគ្គនាយកដ្ឋានកាំកុងត្រូល, នាយកដ្ឋាននីតិកម្ម និងនាយកដ្ឋានពហុភាគី ។ ដូច្នេះ DICO ស្នើឲ្យមានការសហការឲ្យបានល្អជាមួយក្រុមសវនកម្មនេះ។ ក្រុមនេះអាចចុះទៅធ្វើសវនកម្មនៅគ្រប់ IAs តាមការចាំបាច់ ។

## V- ការងាររបស់ផ្នែកលទ្ធកម្ម (Procurement Unit)

### v.i- ការធ្វើបច្ចុប្បន្នភាពស្ថានភាពលទ្ធកម្ម

មន្ត្រីផ្នែកលទ្ធកម្មរបស់ DICO បានបង្ហាញពីវឌ្ឍនភាពនៃការធ្វើលទ្ធកម្មរបស់គម្រោងនីមួយៗជូន IAs ទាំងអស់ (សូមពិនិត្យឯកសារក្នុងឧបសម្ព័ន្ធ I)